អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន

## សិក្ខាសាលាស្តីពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងសិទ្ធិមនុស្សសម្រាប់និស្សិតច្បាប់

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) សហការជាមួយវិទ្យាស្ថានសិទ្ធិមនុស្ស និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ Raoul Wallenberg (RWI) ជាម្ចាស់ផ្ទះរៀបចំសិក្ខាសាលាជាច្រើនស្តីពីប្រធានបទផ្សេងៗជុំវិញច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស។ សិក្ខាសាលាទាំងនេះមានគោលបំណងបង្កើនការយល់ដឹង និងចំណេះដឹងអំពីប្រធានបទទាំងនេះដល់និស្សិតច្បាប់និងសាស្ត្រាចារ្យ/អ្នកស្រាវជ្រាវច្បាប់នៅក្នុងប្រទេសកម្ពុជាព្រមទាំងជាវេទិកាជជែកពិភាក្សារវាងអ្នកច្បាប់នៅ អ.វ.ត.ក និងអ្នកសិក្សាស្រាវជ្រាវ ដើម្បីជួយសម្រួលដល់ការសិក្សាស្រាវជ្រាវ។ សិក្ខាសាលាទី១ នឹងចាប់ផ្តើមនៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ នៅ អ.វ.ត.ក ដោយវគ្គនេះនឹងពិភាក្សាអំពីកេរដំណែលនៃតុលាការអន្តរជាតិដំបូងក្នុងទ្វីបអាស៊ីគឺ“តុលាការយោធាអន្តរជាតិសម្រាប់អាស៊ីចុងបូព៌ា”។

សិក្ខាសាលានេះនឹងត្រូវរៀបចំជា ១០ វគ្គ គ្របដណ្តប់ទៅលើប្រធានបទផ្សេងៗចាប់ពី “ប្រវត្តិ និងវិធីសាស្ត្រនៃការបង្កើតច្បាប់ព្រហ្មទណ្ឌអន្តរជាតិ” រហូតដល់ “សារធាតុនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍” និង “ឯករាជ្យភាព និងអព្យាក្រិតភាពនៃតុលាការ”។ សិក្ខាសាលានីមួយៗនឹងមានរយៈពេលប្រមាណពីរម៉ោង ដោយមានការធ្វើបទបង្ហាញ និងបន្ទាប់ការពិភាក្សា។ វាគ្មិនក្នុងសិក្ខាសាលានេះរួមមានអ្នកជំនាញនៅ អ.វ.ត.ក និងអ្នកសិក្សា ស្រាវជ្រាវមកពីខាងក្រៅដែលមកធ្វើទស្សនកិច្ចនៅ អ.វ.ត.ក។

ផ្អែកលើគោលការណ៍ “អ្នកមកមុន បានទទួលសេវាមុន” យើងខ្ញុំបានជ្រើសរើសនិស្សិតច្បាប់សរុបជាង ៨០ រូប ដែលកំពុងបន្ត ឬទើបតែបញ្ចប់ការសិក្សាថ្មីៗ (ក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅ) នៅសាកលវិទ្យាល័យនានាក្នុងប្រទេសកម្ពុជា ឱ្យចូលរួមក្នុងសិក្ខាសាលានេះ។ និស្សិតដែលបានចូលរួមសិក្ខាសាលាប្រាំបីវគ្គ ឬលើសពីនេះនឹងទទួលបាន “វិញ្ញាបនប័ត្របញ្ជាក់ការចូលរួម” ដែលចេញរួមគ្នាដោយ អ.វ.ត.ក និងវិទ្យាស្ថានសិទ្ធិមនុស្ស និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ Raoul Wallenberg (RWI)។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្ដីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh